ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែធ្នូ ឆ្នាំ២០២៣

នៅក្នុងខែធ្នូ ឆ្នាំ២០២៣នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

១.១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន០១លើក។

១.១.១-បដិសណ្ឋារកិច្ចទ្វេភាគី-អន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម **កៅ យុនឡុង** Gao Yunlong អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

១.១.២-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខ សមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ ទូទាំងខណ្ឌព្រែកព្នៅ ខណ្ឌសែនសុខ និងខណ្ឌកំបូល រាជធានីភ្នំពេញ

-បានអញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងកងកម្លាំងប៉ុស្តិ៍ នៅខេត្តត្បូងឃ្មុំ ខេត្តកំពង់ស្ពឺ និងខេត្តកែប។

១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី៣១ ប្រចាំឆ្នាំ២០២៣ នៅសាកលវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមដង្ហែ និងទទួលព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងបំពេញព្រះរាជទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-បានអញ្ជើញចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព និងគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ឡុង ពៅប្រាជ្ញា** ទីប្រឹក្សាផ្ទាល់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពសីលវិសុទ្ធសិរីវចនាអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **នាង ហ៊ុច** នៅសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

១.១.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០៩ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន០៧ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ កា អនុប្រធានទី១ព្រឹទ្ធសភា**

-បានបំពេញភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន០១លើក។

១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមសិក្ខាសាលា វេទិកា និងកិច្ចប្រជុំនានា ចំនួន០៣លើក។

១.២.២-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន០៨លើក។

១.២.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន២៣ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៨ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចុះមូលដ្ឋាន

-បានចាត់តាំងឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ។

១.៣.២-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យដំណើរការកិច្ចសហប្រតិបត្តិការលើកកម្ពស់ជីវភាពមិត្តភាពកម្ពុជា-ចិន ដើម្បីផលប្រយោជន៍ប្រជាជន ក្រោមក្របខ័ណ្ឌប្រតិបត្តិការជំរុញការតភ្ជាប់ប្រជាជន និងប្រជាជន តាមផ្លូវសូត្រជាមួយឯកឧត្តម Gao Yunlong អនុប្រធានសភាប្រឹក្សា

នយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ នៅសណ្ឋាគារRosewood

-បានអញ្ជើញលៀងសាយភោជនជូនជាកិត្តិយសដល់ឯកឧត្តម Gao Yunlong អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ និងគណៈប្រតិភូ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធព្រះមហាក្សត្រ Sheikh NAWAF AL-AHMADAL-JABER AL-SABAH នៃរដ្ឋគុយវ៉ែត។

១.៣.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០៨ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៨ច្បាប់។

## ៤-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១-មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះសិក្សាឈ្វេងយល់ពីស្ថានភាពនៅមជ្ឈមណ្ឌលភស្តុភារកម្ម និងកំពង់ផែពហុបំណងក្រុមហ៊ុនកំពតឡូជីស្ទីកអេនផត ឯ.ក នៅខេត្តកំពត។

### ៤.២-មុខងារតំណាង

-បានទទួលពាក្យបណ្តឹង ចំនួន០៤ករណី កំពុងពិនិត្យសិក្សា ចំនួន០៨ករណី និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន០២ករណី

-បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី វិធីសាស្ត្របង្ការជំងឺមិនឆ្លង និងវិធានការ ដើម្បីកាត់បន្ថយគម្លាតយេនឌ័រ ដែលបណ្តាលមកពីជំងឺមិនឆ្លង នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ លើសេចក្តីព្រាងរបាយការណ៍ពិនិត្យជាសកលតាមកាលកំណត់(UPR) ជុំទី៤ ជាមួយអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា នៅរាជធានីភ្នំពេញ

-បានអញ្ជើញជាអធិបតី និងចូលរួមសិក្ខាសាលាស្តីពី អត្រានុកូលដ្ឋាន និងការចុះបញ្ជីកំណើតនៅកម្ពុជាដែលរៀបចំដោយសភានៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយសភាប្រើភាសាបារាំង (AFF) ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ និងមជ្ឈមណ្ឌលសភាអាស៊ី នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបើកវេទិកាស្តីពី ការការពារ និងអភិរក្សធនធានធម្មជាតិ ក្រោមប្រធានបទពង្រឹងភាពជាដៃគូឆ្ពោះទៅអព្យាក្រឹតកាបូនសហគមន៍ និងកិច្ចប្រជុំបណ្តាញ

សហគមន៍អភិរក្សធនធានធម្មជាតិ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបើក និងបិទ សិក្ខាសាលាស្តីពីសុវត្ថិភាពសាច់បង្កកសម្រាប់សុខភាពប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមក្នុងជំនួបសម្តែងការគួរសមរវាងសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ជាមួយឯកឧត្តម Gao Yunlong អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញជាកិត្តិយសក្នុងពិធីប្រកាសដាក់ឱ្យដំណើរការកិច្ចសហប្រតិបត្តិការលើកកម្ពស់ជីវភាពមិត្តភាពកម្ពុជា-ចិន សម្រាប់សកម្មភាពផ្សារភ្ជាប់ប្រជាជន និងប្រជាជននៅលើផ្លូវសូត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Gao Yunlong អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន០៤លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ ជំនួបឯកឧត្តម GAO Yunlong អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន ជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ និងគណៈប្រតិភូ, ពិធីបុណ្យសមុទ្រលើកទី១០ ឆ្នាំ២០២៣ ក្រោមប្រធានបទ ទាំងអស់គ្នាដើម្បីទេសចរណ៍, ពិធីបើកការដ្ឋានសាងសង់ចំណតផែកុងតឺន័រទឹកជ្រៅថ្មី ជំហានទី១ និងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការគ្រឿងចក្រលើកដាក់ចល័តនៅគែមផែ ចំនួន០២គ្រឿង របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ, ពិធីអបអរសាទរទិវាជនមានពិការភាពកម្ពុជាលើកទី២៥ និងទិវាជនមានពិការភាពអន្តរជាតិលើកទី៤១ នៅរាជធានីភ្នំពេញ ខេត្តកែប និងខេត្តព្រះសីហនុ

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីប្រារព្ធមហាសន្និបាតកាកបាទក្រហមកម្ពុជាអាណត្តិទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ប្រធានក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមកម្មវិធីទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមក្នុងពិធីប្រកាសឱ្យប្រើប្រាស់កញ្ចប់ឧបករណ៍ និងគោលការណ៍ណែនាំក្នុងការធ្វើមូលដ្ឋានីយកម្មនៃផែនការសកម្មភាពថ្នាក់តំបន់ស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមពិធីរំលឹកខួបលើកទី៧៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស នៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា(OHCHR) នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមកម្មវិធីពិភាក្សា និងពិគ្រោះយោបល់កម្រិតខ្ពស់ជាមួយដៃគូអភិវឌ្ឍន៍ ដែលក្នុងនោះរួមទាំងវិស័យឯកជន អង្គការអន្តរជាតិ និងឯកអគ្គរដ្ឋទូតផងដែរ ដើម្បីផ្សព្វផ្សាយ និងរៀបចំអាទិភាពការងារស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍវិស័យរ៉ែ និងថាមពល នៅរាជធានីភ្នំពេញ

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនិងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន៤០លើក ព្រមទាំងបានអញ្ជើញជាគណៈអធិបតី ក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៩៤លើក។

## ៤.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលសភា កម្ពុជា-ឡាវ-វៀតណាម (CLV) លើកទី១ ស្តីពីការពង្រឹងតួនាទីសភាក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនៃប្រទេសទាំងបី នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-បានអញ្ជើញចូលរួមពិធីទទួល និងជូនដំណើរឯកឧត្តម GAO Yunlong អនុប្រធានសភាប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានមូលនិធិដើម្បីសន្តិភាព និងការអភិវឌ្ឍ អញ្ជើញមកទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូមកពីវេទិកាភាពជាដៃគូដើម្បីបញ្ចប់ជំងឺរបេងនៃប្រទេសកាហ្សាក់ស្ថាន នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យលោក William Van De Put និង Dr Alexander Evangroen ជនជាតិហូឡង់ ចូលជួបពិភាក្សាអំពីគម្រោងវិនិយោគការបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សចាស់ នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីពិសាអាហារសាមគ្គី ជាមួយលោកជំទាវ Devyani Uttam Khobragade ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងពង្រីកចំណងមិត្តភាពកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា-ឥណ្ឌា ក្រោមអធិបតីភាពឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ និងជាប្រធានក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា ជាមួយសភាសាធារណរដ្ឋឥណ្ឌា នៅភោជនីយដ្ឋានក្រវ៉ាញ រាជធានីភ្នំពេញ។៚

ថ្ងៃ ព្រហ ៨ កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

**ឧ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
  (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ